**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ២២ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅរបស់ វិទ្យាស្ថានសិក្សាអន្តរជាតិនិងគោលនយោបាយសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ១៥ អនក្រ.បក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងថវិកានិងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទភ្នំពេញជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើតវិទ្យាស្ថានសិក្សាអន្តរជាតិនិងគោលនយោបាយសាធារណៈ ដែលសរសេរជាអក្សរកាត់ថា **វ.ស.ន.ប.** និងជាភាសាអង់គ្លេសថា Institute for International Studies and Public Policy សរសេរជាអក្សរកាត់ថា IISPP ស្ថិតនៅក្រោមសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

## ជំពូកទី២

## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា២.-**

**វ.ស.ន.ប.** មានតួនាទីជាសេនាធិការឱ្យសាកលវិទ្យាល័យភូមិន្ទភ្នំពេញលើការងារអប់រំ បណ្តុះបណ្តាលបច្ចេកទេស ការងារស្រាវជ្រាវ នវានុវត្តន៍ និងមានភារកិច្ចដូចខាងក្រោម៖

- ស្រាវជ្រាវ ផ្សព្វផ្សាយ និងបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រ និងក្រោយបរិញ្ញាបត្រលើជំនាញទំនាក់ទំនងអន្តរជាតិ សេដ្ឋកិច្ច វិទ្យាសាស្ត្រនយោបាយ និងគោលនយោបាយសាធារណៈ
- ស្រាវជ្រាវលើបញ្ហាក្នុងប្រទេស តំបន់ និងពិភពលោក ដោយប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវពហុមុខវិជ្ជា ផ្អែកលើចំណេះដឹងផ្នែកវិទ្យាសាស្ត្រសង្គមនិងមនុស្សសាស្ត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច វិទ្យាសាស្ត្រនយោបាយ និងគោលនយោបាយសាធារណៈ
- រៀបចំនិងអភិវឌ្ឍកម្មវិធីសិក្សានិងបណ្តុះបណ្តាលគ្រប់កម្រិតរបស់វិទ្យាស្ថាន

- សហការជាមួយស្ថាប័នជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍ ដើម្បីបណ្តុះបណ្តាល ស្រាវជ្រាវ និងផ្សព្វផ្សាយ
- បង្កើតវេទិកាចែករំលែកចំណេះដឹងនិងរៀបចំព្រឹត្តិការណ៍សំខាន់ៗ រួមមានសន្និសីទ សិក្ខាសាលា បាឋកថា និងកិច្ចពិភាក្សាផ្សេងៗ
- ផ្សព្វផ្សាយលទ្ធផលនៃការសិក្សា ការស្រាវជ្រាវ សំឡេងផ្សព្វផ្សាយ បទសន្ទនា បទវិភាគ ការពិគ្រោះយោបល់ និងពហុប្រព័ន្ធផ្សព្វផ្សាយ
- បម្រើជាវេទិកានិងមជ្ឈមណ្ឌលសម្រាប់បញ្ញវន្តនិងអ្នកស្រាវជ្រាវកម្ពុជានិងបរទេស ដើម្បីធ្វើការសិក្សាអំពីបញ្ហាសំខាន់ៗដែលប្រទេសកម្ពុជា តំបន់ និងពិភពលោកកំពុងប្រឈម
- រៀបចំផែនការសម្រាប់អភិវឌ្ឍវិទ្យាស្ថាន
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីសាកលវិទ្យាធិការ។

**មាត្រា៣ .-**

**វ.ស.ន.ប.** មានឋានៈស្មើមហាវិទ្យាល័យដែលដឹកនាំដោយនាយក១(មួយ)រូប តែងតាំងដោយអនុក្រឹត្យ និងមាននាយករងមួយចំនួនជាជំនួយការ តែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤ .-**

**វ.ស.ន.ប.** មានមជ្ឈមណ្ឌលនិងដេប៉ាតឺម៉ង់ ជារចនាសម្ព័ន្ធចំណុះ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលនិងដេប៉ាតឺម៉ង់ចំណុះឱ្យ **វ.ស.ន.ប.** ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣
## អន្តរប្បញ្ញត្តិ

**មាត្រា៥ .-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងការតែងតាំងមន្ត្រីរាជការនិងការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនានាចំណុះដេប៉ាតឺម៉ង់សិក្សាអន្តរជាតិ ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៣ រោច ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ មករា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ